# ព្រះរាជក្រម

នស/រកម/០១១៩/០០២

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីបរធនបាលកិច្ច ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨ នាសម័យប្រជុំរដ្ឋសភា លើកទី១ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨ នាសម័យប្រជុំពេញអង្គលើកទី២ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# បរធនបាលកិច្ច

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .–**

ច្បាប់នេះមានគោលបំណងគ្រប់គ្រងបរធនដែលត្រូវបានបង្កើតឡើងក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ .–**

ច្បាប់នេះមានគោលដៅកំណត់អំពី វិធាន នីតិវិធីនៃការបង្កើត ការចុះបញ្ជី ការគ្រប់គ្រង និងការត្រួតពិនិត្យបរធនបាលកិច្ច។

**មាត្រា៣ .–**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះបរធនបាលកិច្ចដែលត្រូវបានបង្កើតឡើងក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ .–**

បច្ចេកសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

# ជំពូកទី២

## បរធនបាលកិច្ច

## ផ្នែកទី១

## ភាគី ការបង្កើត និងអានុភាពនៃបរធនបាលកិច្ច

**មាត្រា៥ .–**

ភាគីនៃបរធនបាលកិច្ច ជាសំខាន់មាន៣ (បី) គឺ បរធនបាលទាយក បរធនបាល និងអត្ថគាហកៈ។

បរធនបាលកិច្ចអាចមានភាគីចូលរួមផ្សេងទៀតដូចជា អ្នកផ្តល់វិភាគទានបរធនបាលកិច្ច និងបរធនបាលទាយកជំនួស។

**មាត្រា៦ .–**

បរធនបាលកិច្ចត្រូវបានបង្កើតឡើងដោយបរធនបាលទាយកឬបទប្បញ្ញត្តិជាធរមាននិងត្រូវមានកម្មវត្ថុស្របច្បាប់មិនផ្ទុយទៅនឹងសណ្តាប់ធ្នាប់សាធារណៈ។

**មាត្រា៧ .–**

ដំណើរការនៃការបង្កើតបរធនបាលកិច្ចមានដូចខាងក្រោម៖

- ករណីដែលបរធនបាលកិច្ចត្រូវបានបង្កើតឡើងដោយបរធនបាលទាយក បរធនបាលទាយកត្រូវផ្ទេរទ្រព្យសម្បត្តិឬមូលនិធិរបស់ខ្លួនឱ្យទៅបរធនបាល តាមរយៈលិខិតបរធនបាលកិច្ចដោយមានបញ្ជាក់ពីគោលបំណងជាក់លាក់របស់បរធនបាលកិច្ចនិង/ឬបញ្ជាក់ពីអត្តសញ្ញាណអត្ថគាហកៈ។
- ករណីដែលបរធនបាលកិច្ចត្រូវបានបង្កើតឡើងដោយបទប្បញ្ញត្តិជាធរមាន បរធនត្រូវបានផ្ទេរដោយស្វ័យប្រវត្តិឱ្យទៅបរធនបាល ដើម្បីគ្រប់គ្រងនិងចាត់ចែងទ្រព្យសម្បត្តិ ស្របតាមបទប្បញ្ញត្តិជាធរមាន ដោយមានបញ្ជាក់ពីគោលបំណងជាក់លាក់របស់បរធនបាលកិច្ចនិង/ឬបញ្ជាក់ពីអត្តសញ្ញាណអត្ថគាហកៈ។

**មាត្រា៨ .-**

បរធនបាលកិច្ចមានអានុភាពអនុវត្ត នៅពេលដែលបរធនបាលយល់ព្រមទទួលយកជាលាយលក្ខណ៍អក្សរចំពោះការតែងតាំង។

## ផ្នែកទី២
## គោលបំណងនៃបរធនបាលកិច្ច

**មាត្រា៩ .-**

បរធនបាលកិច្ចត្រូវបានបែងចែកជា៤ (បួន)ប្រភេទ ដូចខាងក្រោមៈ

-បរធនបាលកិច្ចពាណិជ្ជកម្ម

-បរធនបាលកិច្ចសាធារណៈ

-បរធនបាលកិច្ចសង្គម

-បរធនបាលកិច្ចបុគ្គល។

**មាត្រា១០ .-**

បរធនបាលកិច្ចពាណិជ្ជកម្មត្រូវបានបង្កើតឡើងក្នុងគោលបំណងស្វែងរកប្រាក់ចំណេញ សម្រាប់ជាប្រយោជន៍ដល់អ្នកផ្តល់វិភាគទានបរធនបាលកិច្ចឬបុគ្គលណាមួយជាក់លាក់ដែលកំណត់ដោយអ្នកផ្តល់វិភាគទានបរធនបាលកិច្ច រួមមានៈ

១-មូលនិធិសោធននិវត្តន៍ មូលនិធិអប់រំ និងមូលនិធិប្រហាក់ប្រហែលផ្សេងទៀតដែលបុគ្គលណាមួយផ្ទេរទ្រព្យសម្បត្តិឱ្យបរធនបាល ហើយត្រូវបានផ្ទេរត្រឡប់ទៅបុគ្គលនោះវិញឬផ្ទេរឱ្យបុគ្គលណាមួយផ្សេងទៀតនៅពេលដែលបានបំពេញតាមលក្ខខណ្ឌមួយចំនួនដូចខាងក្រោមៈ

ក-មានការផ្ទេរទ្រព្យសម្បត្តិឬមូលនិធិទៅក្នុងបរធនបាលកិច្ចដោយបុគ្គលណាម្នាក់ឱ្យទៅបរធនបាលជាប្រចាំ ហើយបរធនបាលគ្រប់គ្រងនិងចាត់ចែងមូលនិធិនេះសម្រាប់ជាប្រយោជន៍ជាក់លាក់របស់បុគ្គលនេះឬបុគ្គលផ្សេងទៀត ហើយ

ខ-នៅពេលដែលទ្រព្យសម្បត្តិឬមូលនិធិរបស់អ្នកផ្តល់វិភាគទានផ្សេងទៀតត្រូវបានដាក់បញ្ចូលក្នុងគម្រោងវិនិយោគ ហើយត្រូវបានវិនិយោគដោយបរធនបាលសម្រាប់ជាប្រយោជន៍របស់អ្នកផ្តល់វិភាគទានទាំងអស់តាមលក្ខខណ្ឌដែលបានកំណត់ និង

គ-នៅពេលដែលទ្រព្យសម្បត្តិនិងផលដែលបានមកពីការវិនិយោគត្រូវបានកំណត់ គ្រប់គ្រង និងរាយការណ៍ដាច់ដោយឡែកទៅបុគ្គលនោះ។

២-សេវារក្សាទុកដែលក្នុងនោះមានការផ្ទេរទ្រព្យសម្បត្តិឬមូលនិធិដោយបុគ្គលណាមួយ ឱ្យទៅបរធនបាល ហើយបរធនបាលត្រូវផ្ទេរត្រឡប់ឱ្យទៅបុគ្គលនេះវិញឬឱ្យទៅបុគ្គលណាមួយផ្សេងទៀត នៅពេលដែលបានបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

ក-មានការរក្សាទុកទ្រព្យសម្បត្តិឬមូលនិធិដោយបុគ្គលណាមួយ ជាអាទិ៍ មន្ទីរសារការី ឬការិយាល័យមេធាវី ឬក្រុមហ៊ុនគណនេយ្យ ឬ

ខ-មានការកាន់កាប់ទ្រព្យសម្បត្តិឬមូលនិធិតម្កល់ដើម្បីជាប្រយោជន៍របស់វិនិយោគិន អ្នកទិញអចលនវត្ថុ និងដើម្បីប្រតិបត្តិការពាណិជ្ជកម្មផ្សេងៗទៀត ឬ

គ-សេវារក្សាទុកផ្សេងទៀតដែលទទួលបានការអនុញ្ញាតតាមសេចក្តីសម្រេចរបស់បញ្ញត្តិករផ្សេងទៀត ជាអាទិ៍ ធនាគារជាតិនៃកម្ពុជា គណៈកម្មការមូលបត្រកម្ពុជា ឬក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីគ្រប់គ្រងសកម្មភាពនានាដែលស្ថិតក្រោមតួនាទីនិងភារកិច្ចរបស់ខ្លួន។

៣-គម្រោងភាគហ៊ុននិយោជិតឬផលប្រយោជន៍និយោជិត នៅពេលដែលបរធនបាល គ្រប់គ្រងទ្រព្យសម្បត្តិឬមូលនិធិដើម្បីវិនិយោគក្នុងនាមនិយោជិតនោះ និង

៤-ដើម្បីគោលបំណងផ្សេងទៀត៖

ក-នៅពេលដែលមានការផ្ទេរទ្រព្យសម្បត្តិឬមូលនិធិដោយបុគ្គលណាមួយឱ្យទៅបរធនបាលសម្រាប់ជាប្រយោជន៍ដល់អ្នកផ្តល់វិភាគទានឬបុគ្គលផ្សេងទៀតដែលកំណត់ដោយអ្នកផ្តល់វិភាគទាន និង

ខ-នៅពេលដែលបទប្បញ្ញត្តិជាធរមាន ចែងអំពីវិធានស្តីពីដំណើរការនិងការគ្រប់គ្រងសកម្មភាពនៃបរធនបាលកិច្ច។

មាត្រា១១

បរធនបាលកិច្ចសាធារណៈត្រូវបានបង្កើតឡើងក្នុងគោលបំណងជាប្រយោជន៍របស់ប្រជាពលរដ្ឋខ្មែរទូទៅ។

បរធនបាលកិច្ចនេះរួមមាន៖

១-ការអភិវឌ្ឍវិស័យធនាគារនិងមីក្រូហិរញ្ញវត្ថុនៅកម្ពុជា នៅពេលដែលៈ

ក-ដៃគូអភិវឌ្ឍផ្តល់ទ្រព្យសម្បត្តិឬមូលនិធិរបស់ខ្លួនសម្រាប់ជាប្រយោជន៍របស់ប្រជាពលរដ្ឋខ្មែរ ហើយទ្រព្យសម្បត្តិឬមូលនិធិទាំងនោះបាននិងកំពុងគ្រប់គ្រងនិងចាត់ចែងនៅក្នុងគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ឬបុគ្គលផ្សេងទៀត និង

ខ-តាមលក្ខខណ្ឌដែលមានកំណត់នៅក្នុងលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

២-ជាប្រយោជន៍សាធារណៈផ្សេងទៀតនៅពេលដែលបញ្ញត្តិករពាក់ព័ន្ធតែងតាំងបរធនបាល ដើម្បីគ្រប់គ្រងនិងការពារមូលនិធិនានាតាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។ លក្ខខណ្ឌទាំងនេះមានជាអាទិ៍ៈ

ក-មូលនិធិដែលបានផ្តល់ឱ្យរាជរដ្ឋាភិបាលឬត្រូវបានផ្តល់ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបំពេញគោលបំណងជាក់លាក់ណាមួយរបស់អ្នកផ្តល់ជំនួយ ហើយអ្នកផ្តល់ជំនួយទាមទារឱ្យមូលនិធិនេះត្រូវបានចាត់ចែងប្រើប្រាស់និងអាស្រ័យផលស្របតាមគោលបំណងរបស់ខ្លួន ឬ

ខ-ត្រូវការពារផលប្រយោជន៍របស់កុមារឬអសមត្ថជនផ្សេងទៀត ឬ

គ-មតិកដែលធ្លាក់ទៅជាទ្រព្យរដ្ឋតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា១២ .-**

បរធនបាលកិច្ចសង្គមត្រូវបានបង្កើតឡើងនៅពេលដែលបរធនបាលទាយកធ្វើប្រទានកម្មទ្រព្យសម្បត្តិរបស់ខ្លួនឱ្យទៅបរធនបាល ដើម្បីប្រើប្រាស់ជាប្រយោជន៍ទូទៅក្នុងសង្គម ដូចជាក្នុងគោលបំណងវប្បធម៌ អប់រំ មនុស្សជាតិ សាសនា ឬវិទ្យាសាស្ត្រ។

១-មូលនិធិពិសេសៈ

ក-មូលនិធិដែលបង្កើតដោយបរធនបាលទាយកតាមរយៈប្រទានកម្មឬមតកសាសន៍

ខ-តាមរយៈការទទួលទ្រព្យសម្បត្តិពីអ្នកផ្តល់វិភាគទានបរធនបាលកិច្ចនៅមានជីវិតឬទទួលទ្រព្យសម្បត្តិតាមមតកសាសន៍របស់អ្នកផ្តល់វិភាគទានបរធនបាលកិច្ច និង

គ-ទ្រព្យសម្បត្តិត្រូវបានផ្ទេរឱ្យទៅបរធនបាល ដើម្បីបំពេញគោលបំណងជាប្រយោជន៍សង្គម និង

ឃ-មិនស្វែងរកប្រាក់ចំណេញឬគ្មានប្រតិបត្តិការជាសហគ្រាសពាណិជ្ជកម្ម និង

ង-លើកលែងតែមានចែងផ្សេងក្នុងលិខិតបរធនបាលកិច្ច ទ្រព្យសម្បត្តិដំបូងនិងទ្រព្យសម្បត្តិបន្ថែមផ្សេងទៀត ដែលអ្នកផ្តល់វិភាគទានបរធនបាលកិច្ចបានផ្ទេរចូលមូលនិធិណាមួយ ត្រូវរក្សាទុកដើម្បីបំពេញគោលបំណងបរធនបាលកិច្ច ហើយអនុញ្ញាតឱ្យចែកចាយតែផលដែលបានពីទ្រព្យសម្បត្តិនោះប៉ុណ្ណោះ។

២-មូលនិធិសម្រាប់ជាប្រយោជន៍ដល់អង្គការវប្បធម៌ អប់រំ មនុស្សជាតិ សាសនា ឬវិទ្យាសាស្ត្រ : ទ្រព្យសម្បត្តិទទួលពីបុគ្គល រួមមានប្រទានកម្ម ឬមតកសាសន៍ ហើយទ្រព្យសម្បត្តិនេះត្រូវបានផ្ទេរដើម្បីបម្រើ

គោលដៅសម្រាប់ជាប្រយោជន៍ ជាអាទិ៍ វប្បធម៌ អប់រំ មនុស្សជាតិ សាសនា ឬវិទ្យាសាស្ត្រ។

**មាត្រា១៣ .–**

បរធនបាលកិច្ចបុគ្គលត្រូវបានបង្កើតឡើងសម្រាប់ជាប្រយោជន៍របស់បរធនបាលទាយកឬបុគ្គលដែលកំណត់ជាក់លាក់ដោយបរធនបាលទាយកតាមលក្ខខណ្ឌដូចខាងក្រោម៖

១-បរធនបាលទាយកជារូបវន្តបុគ្គលដែលធ្វើប្រទានកម្មទ្រព្យសម្បត្តិឬមូលនិធិរបស់ខ្លួន ឱ្យទៅបរធនបាលសម្រាប់ជាប្រយោជន៍របស់ខ្លួនផ្ទាល់ឬរបស់បុគ្គលផ្សេងទៀត ឬ

២-ការផ្ទេរទ្រព្យសម្បត្តិឬមូលនិធិ ដោយបរធនបាលទាយក៖

ក-ករណីបរធនបាលទាយកនៅមានជីវិត បរធនបាលទាយកនោះត្រូវធ្វើលិខិតបរធនបាលកិច្ចដោយមានការបញ្ជាក់ពីសារការី ឬមេធាវី ឬឃុំសង្កាត់ ឬដោយបុគ្គលផ្សេងទៀតដែលមានចែងក្នុងបទប្បញ្ញត្តិជាធរមាន។

ខ-ករណីបរធនបាលទាយកធ្វើមតកសាសន៍ នៅពេលដែលបរធនបាលទាយកនោះទទួលមរណភាពតាមរយៈមតកសាសន៍នេះ បង្កើតជាបរធនបាលកិច្ចដែលស្របតាមបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី។

**មាត្រា១៤ .–**

ការរៀបចំនិងការប្រព្រឹត្តទៅនៃបរធនបាលកិច្ចដែលបានចែងក្នុងមាត្រា១០ មាត្រា១១ មាត្រា១២ និងមាត្រា១៣ ត្រូវកំណត់ដោយបញ្ញត្តិករពាក់ព័ន្ធ។

## ផ្នែកទី៣

## ការកែប្រែគោលបំណងនិងរយៈពេលនៃបរធនបាលកិច្ច

**មាត្រា១៥ .–**

បរធនបាលអាចស្នើសុំកែប្រែគោលបំណងបរធនបាលកិច្ចទៅបញ្ញត្តិករពាក់ព័ន្ធ និងជូនដំណឹងទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អ្នកដាក់ពាក្យស្នើសុំត្រូវបញ្ជាក់៖

- មូលហេតុដែលបរធនបាលកិច្ចមិនបានអនុវត្តតាមគោលបំណងដើម
- ការយល់ព្រមពីបរធនបាលទាយក
- ការយល់ព្រមជាឯកច្ឆន្ទពីបរធនបាល
- ការយល់ព្រមពីបុគ្គលដែលទទួលខុសត្រូវ និង
- លក្ខខណ្ឌនៃលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

**មាត្រា១៦ .–**

រយៈពេលនៃបរធនបាលកិច្ចនីមួយៗត្រូវកំណត់ក្នុងលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

ចំពោះបរធនបាលកិច្ច ក្នុងគោលបំណងជាប្រយោជន៍បុគ្គល រយៈពេលកំណត់មិនត្រូវឱ្យលើសពី ១០០(មួយរយ)ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃការបង្កើតបរធនបាលកិច្ច។

ក្នុងករណីទ្រព្យសម្បត្តិបរធនបាលកិច្ចដែលត្រូវបែងចែកបន្ទាប់ពីបរធនបាលកិច្ចត្រូវបានបញ្ចប់ ប៉ុន្តែអត្ថគាហកៈមិនទាន់ទទួលការអនុញ្ញាតឬសិទ្ធិក្នុងការកាន់កាប់នៃទ្រព្យសម្បត្តិដែលជាដីធ្លី នោះទ្រព្យសម្បត្តិបរធនបាលកិច្ចត្រូវក្លាយជាសិទ្ធិជួល រហូតដល់អត្ថគាហកៈមានសិទ្ធិពេញលេញក្នុងការកាន់កាប់ដីធ្លីស្របតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៣

## បរធនបាលទាយក បរធនបាល និងអត្ថគាហកៈ

## ផ្នែកទី១

## បរធនបាលទាយក

**មាត្រា១៧ .-**

បរធនបាលទាយកមានសិទ្ធិជាអាទិ៍ ដូចខាងក្រោម៖

- ទទួលព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបរធនបាលកិច្ចដែលមានជាអាទិ៍ របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍សវនកម្ម និងឯកសារពាក់ព័ន្ធផ្សេងទៀត
- តែងតាំងនិងបញ្ឈប់បរធនបាល តាមលក្ខខណ្ឌដែលបានកំណត់ក្នុងលិខិតបរធនបាលកិច្ច។

**មាត្រា១៨ .-**

បរធនបាលទាយកមានកាតព្វកិច្ចជាអាទិ៍ ដូចខាងក្រោម៖

- ផ្ទេរទ្រព្យសម្បត្តិឬមូលនិធិជាបរធនឱ្យទៅបរធនបាល គ្រប់គ្រង និងចាត់ចែងជំនួស សម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ
- ចូលរួមឬសម្រួលក្នុងកិច្ចការផ្ទេរបរធនឱ្យទៅបរធនបាល គ្រប់គ្រង និងចាត់ចែង
- ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំពោះការផ្លាស់ប្តូរបរធនបាលទាយកឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច ឬការកែប្រែលក្ខខណ្ឌនៃលិខិតបរធនបាលកិច្ច
- គោរពតាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ចនិងបទប្បញ្ញត្តិជាធរមាន។

**មាត្រា១៩ .-**

ក្នុងករណីដែលបរធនបាលទាយកពុំមានលទ្ធភាពឬសមត្ថភាពជាស្ថាពរក្នុងការអនុវត្តសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួន [illegible]ដែលពាក់ព័ន្ធមានសមត្ថកិច្ចបំពេញមុខងារមួយចំនួន ជាបរធនបាលទាយកជំនួស។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ផ្នែកទី២

# បរធនបាល

**មាត្រា២០ .-**

បុគ្គលដែលអាចតែងតាំងជាបរធនបាលមានដូចជា៖

១- រូបវន្តបុគ្គលឬក្រុមរូបវន្តបុគ្គលដែលមានសមត្ថភាពគ្រប់គ្រាន់តាមក្រមរដ្ឋប្បវេណី ឬ

២- នីតិបុគ្គលឬក្រុមនីតិបុគ្គលស្របច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬ

៣- ក្រុមចម្រុះនៃរូបវន្តបុគ្គលនិងនីតិបុគ្គល។

បុគ្គលខាងលើអាចត្រូវបានតែងតាំងជាបរធនបាលបាន លុះត្រាតែមិនត្រូវបានហាមឃាត់ដើម្បីធ្វើជាបរធនបាល ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

ចំពោះបរធនបាលកិច្ចដែលបរធនបាលទាយកជារូបវន្តបុគ្គល បរធនបាលទាយកនិង/ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ចនិងអត្ថគាហកៈអាចក្លាយជាបរធនបាល។ ប៉ុន្តែដើម្បីជៀសវាងទំនាស់ផលប្រយោជន៍បរធនបាលទាយកនិង/ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច និងអត្ថគាហកៈ មិនអាចក្លាយជាបរធនបាលក្នុងពេលតែមួយបានឡើយ ហើយត្រូវតែងតាំងបរធនបាលមួយផ្សេងទៀត។

**មាត្រា២១ .-**

បរធនបាលមានសិទ្ធិជាអាទិ៍ដូចខាងក្រោម៖

- ទទួលលាភការឬកម្រៃនានាក្នុងការគ្រប់គ្រងបរធនបាលកិច្ច ដែលអាចប្រែប្រួលទៅតាមបទពិសោធការងារនិង/ឬគុណវុឌ្ឍិវិជ្ជាជីវៈរបស់ខ្លួន
- គ្រប់គ្រងនិងចាត់ចែងបរធនតាមគោលបំណងនិងលក្ខខណ្ឌនៃលិខិតបរធនបាលកិច្ច
- ចំណាយក្នុងសកម្មភាពសង្គម ស្របតាមគោលបំណងនិងលក្ខខណ្ឌនៃលិខិតបរធនបាលកិច្ច
- ស្វែងរកជំនួយឬមូលនិធិផ្សេងៗដើម្បីជាប្រយោជន៍របស់បរធនបាលកិច្ច
- តំណាងឱ្យបរធនបាលទាយកឬអត្ថគាហកៈនៅចំពោះមុខច្បាប់ ឬអាជ្ញាធរមានសមត្ថកិច្ច និង
- គោរពតាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

**មាត្រា២២ .-**

បរធនបាលមានកាតព្វកិច្ចជាអាទិ៍ដូចខាងក្រោម៖

- ដាក់ពាក្យចុះបញ្ជីបរធនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមបែបបទ និងនីតិវិធីដូចមានចែងក្នុងមាត្រា២៨នៃច្បាប់នេះ
- បែងចែកឱ្យបានច្បាស់លាស់រវាងទ្រព្យសម្បត្តិផ្ទាល់ខ្លួននិងទ្រព្យសម្បត្តិបរធនបាលកិច្ច
- គ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ចដោយយកចិត្តទុកដាក់និងដោយប្រុងប្រយ័ត្ន

- រក្សាភាពស្មោះត្រង់និងសុចរិត ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ច
- មិនអាចផ្ទេរមុខងាររបស់ខ្លួនឱ្យទៅបុគ្គលផ្សេងទៀតបានឡើយ
- គ្រប់គ្រងនិងចាត់ចែងលើទ្រព្យសម្បត្តិបរធនបាលកិច្ចឱ្យមានប្រសិទ្ធភាពនិងសក្តិសិទ្ធភាព ដើម្បីជាប្រយោជន៍របស់អត្ថគាហកៈ
- ចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិបរធនបាលកិច្ច
- រាយការណ៍និងផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបរធនបាលកិច្ចឱ្យបរធនបាលទាយក អត្ថគាហកៈ និងបញ្ញត្តិករពាក់ព័ន្ធ
- រក្សាកំណត់ហេតុនៃកិច្ចប្រជុំ រៀបចំគណនីប្រចាំឆ្នាំ និងឆ្លើយតបទៅនឹងបញ្ញត្តិករពាក់ព័ន្ធ
- ចាត់វិធានការសមស្របដើម្បីការពារទ្រព្យសម្បត្តិបរធនបាលកិច្ច និងអត្ថគាហកៈ
- បង់ពន្ធគ្រប់ប្រភេទដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិបរធនបាលកិច្ច
- ចុះកិច្ចសន្យាធានារ៉ាប់រងលើការទទួលខុសត្រូវក្នុងមុខងារជាបរធនបាល
- ផ្តល់របាយការណ៍ហិរញ្ញវត្ថុជាប្រចាំទៅបញ្ញត្តិករពាក់ព័ន្ធនិងទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- មិនអាចទទួលយកផលប្រយោជន៍ពីតតិយជនបានឡើយ ក្នុងករណីមានទំនាស់ផលប្រយោជន៍ និង
- គោរពតាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន។

**មាត្រា២៣ .-**

បរធនបាលមានការទទួលខុសត្រូវចំពោះសកម្មភាពដូចខាងក្រោមៈ

- ការធ្វើឱ្យបាត់បង់ឬថយចុះនៃបរធនដោយគ្មានមូលហេតុត្រឹមត្រូវ
- ការខកខានមិនបានបង្គរប្រាក់ចំណេញទុកក្នុងបរធន ក្នុងករណីដែលទ្រព្យសម្បត្តិបរធនបាលកិច្ច នោះអាចផ្តល់ប្រាក់ចំណេញបាន
- ការប្រើប្រាស់បរធនខុសពីគោលបំណងបរធនបាលកិច្ច
- កំហុសដែលបានប្រព្រឹត្តដោយចេតនាឬអចេតនា ក្នុងការបំពេញការងាររបស់ខ្លួន
- ការទទួលខុសត្រូវផ្សេងទៀត តាមលក្ខខណ្ឌនៃលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

**មាត្រា២៤ .-**

ក្នុងការអនុវត្តសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួន ប្រសិនបើបរធនបាលមិនអាចព្រមព្រៀងគ្នាដោយសំឡេងភាគច្រើន បរធនបាលត្រូវមានៈ

- [illegible]ភាពខ្វែងគំនិតគ្នាជាលាយលក្ខណ៍អក្សរ
- [illegible]ជូន[illegible]ភ្លាមពីភាពខ្វែងគំនិតគ្នានេះជាលាយលក្ខណ៍អក្សរទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ [illegible]បញ្ញត្តិករពាក់ព័ន្ធ។

- បញ្ញត្តិករពាក់ព័ន្ធត្រូវដោះស្រាយវិវាទនេះ ដោយមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៥ .-**

បរធនបាលអាចត្រូវបានជំនួសដោយបុគ្គលផ្សេងទៀតតាមលក្ខខណ្ឌនិងនីតិវិធីដែលមានចែងក្នុងលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

ករណីដែលគ្មានចែងអំពីលក្ខខណ្ឌនិងនីតិវិធីដូចមានចែងក្នុងកថាខណ្ឌទី១ បរធនបាលត្រូវបានជំនួសតាមលក្ខខណ្ឌដូចខាងក្រោមៈ

១-បើបរធនបាលជារូបវន្តបុគ្គល បរធនបាលនេះត្រូវបានជំនួសៈ

ក-ជាស្វ័យប្រវត្តិ នៅពេលដែលខ្លួនទទួលមរណភាព អសមត្ថភាពផ្លូវកាយឬផ្លូវចិត្ត ត្រូវបានប្រកាសដោយអាជ្ញាធរមានសមត្ថកិច្ចថាក្ស័យធន ប្រព្រឹត្តបទល្មើសមជ្ឈិមឬឧក្រិដ្ឋ ឬតាមលក្ខខណ្ឌផ្សេងទៀត ដែលកំណត់ដោយបទប្បញ្ញត្តិជាធរមានរបស់បញ្ញត្តិករពាក់ព័ន្ធ។

ខ-តាមសេចក្តីសម្រេចភាគច្រើនដាច់ខាតរបស់បរធនបាលទាំងអស់ នៅពេលដែលបរធនបាលចូលនិវត្តន៍ ឬបដិសេធមិនបំពេញការងារ ឬមិនសក្តិសមបំពេញការងារ។

២-បើបរធនបាលជានីតិបុគ្គលបរធនបាលនេះត្រូវបានជំនួសនៅពេលដែលបរធនបាលបញ្ឈប់សកម្មភាពរបស់ខ្លួន ហើយត្រូវបានជម្រះបញ្ជីឬត្រូវបានរំលាយ។

បញ្ញត្តិករពាក់ព័ន្ធជាអ្នកចេញសេចក្តីសម្រេចតែងតាំងបរធនបាលជំនួស ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៣

## អត្ថគាហកៈ

**មាត្រា២៦ .-**

អត្ថគាហកៈអាចជាបុគ្គលដែលត្រូវបានបង្កើតស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជាឬអាចជាបរធនបាលទាយក។

អត្ថគាហកៈអាចទទួលផលពីបរធនបាលកិច្ចចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃបរធនបាលកិច្ចលើកលែងតែមានបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

ករណីដែលមានអត្ថគាហកៈច្រើន អត្ថគាហកៈទាំងនេះអាចទទួលផលដូចគ្នាឬផ្សេងៗពីគ្នាតាមរបៀបឬវិធីដែលមានចែងក្នុងលិខិតបរធនបាលកិច្ច។

ករណីដែលគ្មានរបៀបឬវិធីទទួលផលដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវសន្មតថាអត្ថគាហកៈទាំងនេះទទួលផលស្មើៗគ្នា។

**មាត្រា២៧ .-**

អគ្គគាហកៈមានសិទ្ធិជាអាទិ៍ដូចខាងក្រោមៈ

- ទទួលអត្ថប្រយោជន៍ដូចដែលមានចែងក្នុងលិខិតបរធនបាលកិច្ច
- ទាមទារឱ្យបរធនបាលបំពេញកាតព្វកិច្ចដែលបានកំណត់ក្នុងលិខិតបរធនបាលកិច្ចនិងតាមបទប្បញ្ញត្តិជាធរមាន
- ទទួលព័ត៌មានដែលពាក់ព័ន្ធនឹងការគ្រប់គ្រងនិងចាត់ចែងនៃបរធនបាលកិច្ច និង
- សិទ្ធិផ្សេងៗទៀតដែលមានចែងក្នុងលិខិតបរធនបាលកិច្ចនិងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៤

## ការចុះបញ្ជីបរធន ការត្រួតពិនិត្យនិងការបញ្ចប់បរធនបាលកិច្ច

## ផ្នែកទី១

## ការចុះបញ្ជីបរធន

**មាត្រា២៨ .-**

បរធនបាលកិច្ចទាំងអស់មានសុពលភាព លុះត្រាតែចុះបញ្ជីនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងរយៈពេលមិនលើសពី៣(បី)ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការបង្កើតបរធនបាលកិច្ច។

លក្ខខណ្ឌនិងនីតិវិធីលម្អិតនៃការចុះបញ្ជីត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៩ .-**

មុននឹងធ្វើការចុះបញ្ជីសម្រាប់ប្រតិបត្តិករបរធនបាលកិច្ចនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្របតាមមាត្រា២៨នៃច្បាប់នេះ ការបង្កើតបរធនបាលកិច្ចដើម្បីគោលបំណងណាមួយនៃច្បាប់នេះ ត្រូវមានការអនុញ្ញាតជាគោលការណ៍ជាមុនពីបញ្ញត្តិករពាក់ព័ន្ធ។

ការធ្វើប្រតិបត្តិការនៃបរធនបាលកិច្ចស្របតាមគោលបំណងនៃច្បាប់នេះត្រូវមានអាជ្ញាបណ្ណពីបញ្ញត្តិករពាក់ព័ន្ធស្របតាមបទប្បញ្ញត្តិដែលមានជាធរមាន។

**មាត្រា៣០ .-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវកត់ត្រា គ្រប់គ្រង និងរក្សាទុកនូវរាល់ព័ត៌មានរបស់បរធនបាលទាយក បរធនបាល អគ្គគាហកៈ បុគ្គលផ្សេងទៀតដែលពាក់ព័ន្ធ ប្រតិវេទន៍ប្រចាំឆ្នាំ ការផ្លាស់ប្តូរបរធនបាល និងព័ត៌មានចាំបាច់ផ្សេងៗពាក់ព័ន្ធនឹងការចុះបញ្ជី។

លក្ខខណ្ឌនិងនីតិវិធីធ្វើប្រតិវេទន៍ប្រចាំឆ្នាំ និងសេចក្តីជូនដំណឹងពីការផ្លាស់ប្តូរបរធនបាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី២
## ការត្រួតពិនិត្យនិងការបញ្ចប់បរធនបាលកិច្ច

**មាត្រា៣១ .-**

រាល់ប្រតិបត្តិការនៃបរធនបាលកិច្ចត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់បញ្ញត្តិករពាក់ព័ន្ធ ដើម្បីការពារការប្រើប្រាស់បរធនឱ្យស្របតាមគោលបំណងបរធនបាលកិច្ច។

ករណីចាំបាច់ដែលមិនមានការកំណត់ផ្សេងពីនេះពីបញ្ញត្តិករពាក់ព័ន្ធ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចតម្រូវឱ្យធ្វើសវនកម្មលើការគ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ចដោយសវនករឯករាជ្យ។ សវនករឯករាជ្យត្រូវមានការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយចំណាយលើសវនកម្មជាបន្ទុករបស់បរធនបាលកិច្ច។

តាមសំណើរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមិនមានការកំណត់ផ្សេងពីនេះពីបញ្ញត្តិករពាក់ព័ន្ធ បរធនបាលត្រូវអនុញ្ញាតឱ្យមានការត្រួតពិនិត្យលើកំណត់ត្រាបរធនបាលកិច្ចនិងផ្តល់របាយការណ៍ហិរញ្ញវត្ថុ ឬព័ត៌មានផ្សេងទៀត។

**មាត្រា៣២ .-**

បរធនបាលកិច្ចត្រូវបានបញ្ចប់ ក្នុងករណីដូចខាងក្រោម៖

- ការមកដល់នៃកាលាវសានដែលកំណត់នៅក្នុងលិខិតបរធនបាលកិច្ច
- បានសម្រេចគោលបំណងរបស់បរធនបាលកិច្ច
- ការសម្រេចដោយឆន្ទានុសិទ្ធិឬមតិជាឯកច្ឆន្ទរបស់បរធនបាលទាយក
- តាមសេចក្តីសម្រេចរបស់តុលាការមានសមត្ថកិច្ច ឬ
- តាមករណីផ្សេងទៀតដូចមានចែងក្នុងលិខិតបរធនបាលកិច្ច។

**មាត្រា៣៣ .-**

នៅពេលបញ្ចប់បរធនបាលកិច្ច បរធនបាលត្រូវប្រគល់របាយការណ៍នៃការគ្រប់គ្រងបរធនបាលកិច្ចទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឬបញ្ញត្តិករពាក់ព័ន្ធដោយលម្អិតអំពីព័ត៌មាននៃបរធនដែលនៅសល់ ចំណូល ចំណាយ និងព័ត៌មានដែលចាំបាច់ផ្សេងទៀត ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

បរធនបាលកិច្ចត្រូវបន្តអានុភាពអនុវត្តរហូតដល់បញ្ចប់ការជម្រះបញ្ជី ហើយដែលអ្នកជម្រះបញ្ជីត្រូវត្រូវធ្វើឡើងដោយបុគ្គលដែលទទួលខុសត្រូវត្រួតពិនិត្យបរធនបាលកិច្ច។

បរធននៅសល់ក្រោយពីការជម្រះបញ្ជីត្រូវបែងចែកឬផ្តល់ឱ្យទៅបរធនបាលទាយកឬបុគ្គលផ្សេងទៀត ដូចមានចែងក្នុងលិខិតបរធនបាលកិច្ចឬទុកជាទ្រព្យសម្បត្តិរដ្ឋ។

## ជំពូកទី៥
## ការដោះស្រាយវិវាទនិងការធ្វើអធិការកិច្ច
## ផ្នែកទី១
## ការដោះស្រាយវិវាទ

**មាត្រា៣៤ .-**

វិវាទពាក់ព័ន្ធនឹងប្រតិបត្តិការនៃបរធនបាលកិច្ច ត្រូវដោះស្រាយដោយក្រុមប្រឹក្សាដោះស្រាយវិវាទបរធនបាលកិច្ចនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងតែមានការកំណត់ផ្សេងពីនេះដោយបញ្ញត្តិករពាក់ព័ន្ធ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយវិវាទជាកម្មវត្ថុនៃបណ្តឹងរដ្ឋបាលឬបណ្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតពីថ្ងៃចេញសេចក្តីសម្រេច។

ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាដោះស្រាយវិវាទនេះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី២
## ការធ្វើអធិការកិច្ច

**មាត្រា៣៥ .-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសិទ្ធិចាត់តាំងមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ដើម្បីតាមដាន ស្រាវជ្រាវ ត្រួតពិនិត្យ និងជំរុញការអនុវត្តច្បាប់នេះ។

មន្ត្រីអធិការកិច្ចបរធនបាលកិច្ចមានសិទ្ធិធ្វើអធិការកិច្ចលើបរធនបាលកិច្ចនិងបំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មន្ត្រីអធិការកិច្ចបរធនបាលកិច្ចមានសិទ្ធិតាមដាន ត្រួតពិនិត្យ ស្រាវជ្រាវ និងស៊ើបអង្កេតបទល្មើសក្នុងវិស័យបរធនបាលកិច្ច។

**មាត្រា៣៦ .-**

មន្ត្រីអធិការកិច្ចបរធនបាលកិច្ចទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើសដែលមានចែងក្នុងច្បាប់នេះ ដោយអនុវត្តឱ្យស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីអធិការកិច្ចបរធនបាលកិច្ចត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣៧ .-**

ក្នុងក្របខ័ណ្ឌនៃប្រតិបត្តិការទាក់ទងនឹងការពិនិត្យនិងការស៊ើបអង្កេតបទល្មើសដែលមានចែងក្នុងច្បាប់នេះ មន្ត្រីអធិការកិច្ចបរធនបាលកិច្ចមានសិទ្ធិអំណាចធ្វើការឆែកឆេរ ចាប់យកវត្ថុតាង កោះហៅបុគ្គលពាក់ព័ន្ធ និងបំពេញកិច្ចនីតិវិធីដទៃទៀត ដោយអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងករណីចាំបាច់ដែលត្រូវឃាត់ខ្លួនជនសង្ស័យ មន្ត្រីអធិការកិច្ចបរធនបាលកិច្ចត្រូវទទួលការអនុញ្ញាតជាបឋមពីព្រះរាជអាជ្ញា ទោះបីជាការអនុញ្ញាតដោយផ្ទាល់មាត់ក៏ដោយ។

រាល់ប្រតិបត្តិការរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ច ក្នុងការពិនិត្យ ស៊ើបអង្កេតបទល្មើស និងការឃាត់ខ្លួនជនសង្ស័យត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

មន្ត្រីអធិការកិច្ចបរធនបាលកិច្ច មានសិទ្ធិស្នើសុំជំនួយពីរដ្ឋបាលថ្នាក់ក្រោមជាតិនិងអង្គភាពប្រដាប់អាវុធឬអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដែលមានចែងក្នុងច្បាប់នេះ។

**មាត្រា៣៨ .-**

នៅក្នុងដំណើរការអធិការកិច្ចបរធនបាលកិច្ច ក្នុងករណីមានភស្តុតាងឬលទ្ធផលវិភាគផ្ទៀងផ្ទាត់ បញ្ជាក់ថាមានការធ្វើបរធនបាលកិច្ចដែលផ្ទុយពីការអះអាងនិងការផ្តល់សិទ្ធិនៅក្នុងលិខិតបរធនបាលកិច្ច មន្ត្រីអធិការកិច្ចបរធនបាលកិច្ចមានសិទ្ធិចាត់វិធានការផ្អាកជាបណ្តោះអាសន្ន។

**មាត្រា៣៩ .-**

បុគ្គលណាដែលមិនសុខចិត្តចំពោះវិធានការណាមួយរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ច អាចប្តឹងតវ៉ាក្នុងរយៈពេល៣០(សាមសិប)ថ្ងៃទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គិតចាប់ពីថ្ងៃបានទទួលសេចក្តីសម្រេច។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលពាក្យប្តឹង។

ក្នុងករណីបុគ្គលនោះមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បុគ្គលនោះមានសិទ្ធិធ្វើបណ្តឹងទៅតុលាការតាមនីតិវិធី ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលសេចក្តីសម្រេច។

**មាត្រា៤០ .-**

នៅពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីអធិការកិច្ចបរធនបាលកិច្ច ត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសម្គាល់និងសញ្ញាសក្តិ និងត្រូវមានលិខិតបញ្ជាបេសកកម្ម។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ច ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៤១ .-**

បែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចបរធនបាលកិច្ច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤២ .-**

មន្ត្រីអធិការកិច្ចបរធនបាលកិច្ចដែលបំពេញមុខងារនិងភារកិច្ចត្រឹមត្រូវតាមច្បាប់ត្រូវបានការពារដោយច្បាប់។

## ជំពូកទី៦
## ទោសប្បញ្ញត្តិ

**មាត្រា៤៣ .-**

បរធនបាលដែលធ្វើប្រតិបត្តិការដោយមិនបានមកស្នើសុំចុះបញ្ជីបរធន ដូចមានកំណត់ក្នុងមាត្រា២៨ នៃច្បាប់នេះ ត្រូវផាកពិន័យជាប្រាក់ដោយមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ពី២០ ០០០ ០០០(ម្ភៃលាន)រៀល ទៅ៥០ ០០០ ០០០(ហាសិបលាន)រៀល និងត្រូវបញ្ឈប់សកម្មភាពបរធនបាលកិច្ចជាបន្ទាន់ រួចតម្រូវឱ្យមកចុះបញ្ជីបរធននៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥០ ០០០ ០០០(ហាសិបលាន)រៀលទៅ ១០០ ០០០ ០០០(មួយរយលាន)រៀលនិង/ឬដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំ។

**មាត្រា៤៤ .-**

បរធនបាលត្រូវផាកពិន័យជាប្រាក់ដោយមន្ត្រីអធិការកិច្ចបរធនបាលកិច្ច ពី ២០ ០០០ ០០០(ម្ភៃលាន)រៀល ទៅ ៥០ ០០០ ០០០(ហាសិបលាន)រៀល ចំពោះអំពើដូចខាងក្រោម៖

- មិនបានរាយការណ៍និងផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបរធនបាលកិច្ច ឱ្យបរធនបាលទាយកអត្ថគាហកៈនិងបញ្ញត្តិករពាក់ព័ន្ធ។
- មិនផ្តល់របាយការណ៍ហិរញ្ញវត្ថុជាប្រចាំទៅបញ្ញត្តិករពាក់ព័ន្ធ និងទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្នុងករណីមិនរាងចាលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥០ ០០០ ០០០(ហាសិបលាន)រៀលទៅ ១០០ ០០០ ០០០(មួយរយលាន)រៀលនិង/ឬដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំ។

**មាត្រា៤៥ .-**

ត្រូវផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចំពោះបុគ្គលទាំងឡាយណាដែលប្រព្រឹត្តអំពើណាមួយក្នុងវិស័យបរធនបាលកិច្ច ក្នុងចំណោមអំពើដូចខាងក្រោម៖

១- វិលោភលើទំនុកចិត្តឬរំលោភអំណាចក្នុងការបំពេញមុខងាររបស់បរធនបាល ក្នុងគោលបំណងទទួលផលប្រយោជន៍ផ្ទាល់ខ្លួនឬដល់តតិយជនឬក្នុងគោលបំណងធ្វើឱ្យខូចប្រយោជន៍ដល់ភាគីពាក់ព័ន្ធ។

២- ឆបោកក្នុងវិស័យបរធនបាលកិច្ចដែលប្រព្រឹត្តដោយបរធនបាល។

៣- រារាំងឬជ្រៀតជ្រែកដល់មន្ត្រីអធិការកិច្ចក្នុងការបំពេញមុខងារដូចមានចែងក្នុងមាត្រា៣៥នៃច្បាប់នេះ។

៤- ក្លែងបន្លំឯកសារ ឬបំភ័ន្តក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬផ្សព្វផ្សាយឬផ្តល់ព័ត៌មានមិនពិតប្រព្រឹត្តដោយបរធនបាល ដែលនាំឱ្យខូចផលប្រយោជន៍ដល់ភាគីពាក់ព័ន្ធ។

៥- បំផ្លាញឯកសារភស្តុតាងនៃបទល្មើសក្នុងវិស័យបរធនបាលកិច្ច ក្នុងគោលបំណងធ្វើជាឧបសគ្គដល់ការស្រាវជ្រាវរបស់មន្ត្រីអធិការកិច្ចឬមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត។

**មាត្រា៤៦ .-**

បរធនបាលដែលមានចេតនាផ្តល់ព័ត៌មានមិនពិត ក្នុងការចុះបញ្ជីបរធនដំបូងឬចុះបញ្ជីបរធនបន្ត ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥០ ០០០ ០០០(ហាសិបលាន)រៀលទៅ២០០ ០០០ ០០០(ពីររយលាន)រៀលនិង/ឬដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែទៅ៣(បី)ឆ្នាំ។

**មាត្រា៤៧ .-**

បុគ្គលឬបរធនបាលដែលចូលរួមប្រព្រឹត្តបទល្មើសទាក់ទងនឹងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ត្រូវផ្តន្ទាទោសដោយអនុលោមតាមច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន។

**មាត្រា៤៨ .-**

បរធនបាលដែលទម្លាយការសម្ងាត់វិជ្ជាជីវៈដែលបណ្តាលឱ្យខូចផលប្រយោជន៍ភាគីពាក់ព័ន្ធត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥០ ០០០ ០០០(ហាសិបលាន)រៀលទៅ១០០ ០០០ ០០០(មួយរយលាន)រៀលនិង/ឬដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំ។

**មាត្រា៤៩ .-**

នីតិបុគ្គលអាចប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ ស្តីពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គលនៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងកថាខណ្ឌទី២នៃមាត្រា៤៣ កថាខណ្ឌទី២នៃមាត្រា៤៤ និងចំណុចទី១ ទី៤ និងទី៥នៃមាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៨ នៃច្បាប់នេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥០ ០០០ ០០០(ហាសិបលាន)រៀលទៅ២០០ ០០០ ០០០(ពីររយលាន)រៀល និងមិនអនុញ្ញាតឱ្យធ្វើជាបរធនបាលនៅព្រះរាជាណាចក្រកម្ពុជា ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨ ស្តីពីទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គលនៃក្រមព្រហ្មទណ្ឌ។

**មាត្រា៥០ .-**

ចំពោះរូបវន្តបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រា៤៣ កថាខណ្ឌទី២ នៃមាត្រា៤៤ និងមាត្រា៤៥ដល់មាត្រា៤៨នៃច្បាប់នេះ តុលាការអាចប្រកាសទោសបន្ថែមមួយឬច្រើន ដូចមានចែងក្នុងមាត្រា៥៤(ប្រភេទទោសបន្ថែម)នៃក្រមព្រហ្មទណ្ឌ ដោយរួមទាំងការសម្រេចមិនអនុញ្ញាតឱ្យធ្វើជាបរធនបាលនៅព្រះរាជាណាចក្រកម្ពុជា។

ខ្លឹមសារ បែបបទ និងនីតិវិធីសម្រាប់ការអនុវត្តទោសបន្ថែមទាំងនេះ ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ។

**មាត្រា៥១ .-**

ចំពោះបទល្មើសទាំងឡាយណាដែលពុំមានចែងនៅក្នុងច្បាប់នេះត្រូវអនុវត្តតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា៥២ .-**

បុគ្គលដែលទទួលរងឥទ្ធិពលដោយផ្ទាល់ពីសេចក្តីសម្រេចរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ចដូចមានចែងនៅក្នុងជំពូកនេះ អាចប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលសេចក្តីសម្រេច។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលពាក្យប្ដឹង។

ក្នុងករណីបុគ្គលនោះមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បុគ្គលនោះមានសិទ្ធិធ្វើបណ្តឹងទៅតុលាការតាមនីតិវិធីក្នុងរយៈពេល៣០(សាមសិប)ថ្ងៃគិតចាប់ពីថ្ងៃបានទទួលសេចក្តីសម្រេច។

**មាត្រា៥៣ .-**

បទប្បញ្ញត្តិនៃជំពូកទោល (បទប្បញ្ញត្តិទូទៅ)នៃមាតិកាទី១ (បទប្បញ្ញត្តិទូទៅ) ជំពូកទោល (ការបង្ខំដល់រូបកាយ)នៃមាតិកាទី៣(ការបង្ខំដល់រូបកាយ)នៃគន្ថីទី៨នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្តក្នុងករណីដែលសេចក្តីសម្រេចអំពីការផាកពិន័យបានចូលជាស្ថាពរ។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**មាត្រា៥៤ .-**

ក្នុងរយៈពេល៣(បី)ខែ បន្ទាប់ពីច្បាប់នេះចូលជាធរមាន បុគ្គលដែលបាននិងកំពុងគ្រប់គ្រងបរធនបាលកិច្ច ត្រូវមកចុះបញ្ជីបរធនបាលកិច្ច ដូចមានចែងក្នុងមាត្រា២៨នៃច្បាប់នេះ។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**មាត្រា៥៥ .-**

បរធនបាលកិច្ចហិរញ្ញវត្ថុដែលបានមកចុះបញ្ជីដោយអនុក្រឹត្យលេខ៤៧៦ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ ស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ ត្រូវតែបញ្ចូលទៅក្រោមច្បាប់នេះបន្ទាប់ពីចូលជាធរមាន។

**មាត្រា៥៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៧ .-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ ពុធ ១១រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០២ ខែ មករា ឆ្នាំ២០១៩

នស/រកម.០១១៩.០០២

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# ឧបសម្ព័ន្ធនៃច្បាប់ស្ដីពីបរធនបាលកិច្ច
## សទ្ទានុក្រម

បច្ចេកសព្ទសំខាន់ៗជាសារវន្ត ដែលត្រូវបានប្រើក្នុងច្បាប់ស្ដីពីបរធនបាលកិច្ចមាននិយមន័យដូចតទៅះ

១- **ក្រមរដ្ឋប្បវេណី** សំដៅដល់ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

២- **ក្រមព្រហ្មទណ្ឌ** សំដៅដល់ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

៣- **ក្រមនីតិវិធីព្រហ្មទណ្ឌ** សំដៅដល់ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

៤- **ទ្រព្យសម្បត្តិ** សំដៅដល់ចលនវត្ថុនិងអចលនវត្ថុដែលបានកំណត់ក្នុងមាត្រា១២០នៃក្រមរដ្ឋប្បវេណី។

៥- **ទ្រព្យសម្បត្តិបរធនបាលកិច្ច** សំដៅដល់ទ្រព្យសម្បត្តិឬមូលនិធិដែលបានផ្ទេរទៅក្នុងបរធនបាលកិច្ច និងផលដែលបានពីទ្រព្យសម្បត្តិឬមូលនិធិនោះ។

៦- **បរធន** សំដៅដល់ទ្រព្យសម្បត្តិឬមូលនិធិដែលបានផ្ទេរទៅឱ្យបរធនបាលគ្រប់គ្រងនិងចាត់ចែងសម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ តាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

៧- **បរធនបាល** សំដៅដល់បុគ្គលដែលទទួលសិទ្ធិគ្រប់គ្រងនិងចាត់ចែងបរធនពីបរធនបាលទាយកសម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ ដោយអនុលោមតាមលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

៨- **បរធនបាលកិច្ច** សំដៅដល់កិច្ចការគ្រប់គ្រងនិងចាត់ចែងបរធនដែលផ្ដល់ដោយបរធនបាលទាយកសម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ ដោយអនុលោមតាមលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

៩- **បរធនបាលទាយក** សំដៅដល់បុគ្គលដែលបង្កើតនិងកំណត់លក្ខខណ្ឌនៃបរធនបាលកិច្ច និងផ្ដល់ទ្រព្យសម្បត្តិឬមូលនិធិដំបូងទៅក្នុងបរធនបាលកិច្ច។

១០- **បុគ្គល** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលណាមួយដែលត្រូវបានបង្កើតឡើងដោយស្របច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ទោះជាបុគ្គលនោះស្វែងរកប្រាក់ចំណេញឬមិនស្វែងរកប្រាក់ចំណេញ។

១១- **បទានកម្ម** សំដៅដល់កិច្ចសន្យាដែលភាគីម្ខាងបង្ហាញឆន្ទៈផ្ដល់ឱ្យភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិដោយមិនគិតថ្លៃ ហើយភាគីម្ខាងទៀតយល់ព្រមទទួល។

១២- **មតកសាសន៍** សំដៅដល់លិខិតបណ្តាំដែលបុគ្គលបានធ្វើឡើងតាមទម្រង់ដែលកំណត់ដោយច្បាប់ដើម្បីសម្តែងឆន្ទៈចុងក្រោយអំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនជាអាទិ៍ បន្ទាប់ពីមរណភាព។

១៣- **លិខិតបរធនបាលកិច្ច** សំដៅដល់៖

ក- លិខិតគតិយុត្តដែលកំណត់ជាអាទិ៍អំពីការបង្កើត ការគ្រប់គ្រង ការចាត់ចែង និងការបញ្ចប់បរធនបាលកិច្ច ដែលត្រូវបានធ្វើឡើងរវាងបរធនបាលទាយកឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច និងបរធនបាល ដោយមានការបញ្ជាក់ពីសារការី ឬមេធាវី ឬឃុំសង្កាត់ ឬដោយបុគ្គលផ្សេងទៀតដែល មានចែងក្នុងបទប្បញ្ញត្តិជាធរមាន។

ខ- មតកសាសន៍ដែលធ្វើឡើងស្របតាមបទប្បញ្ញត្តិស្តីពីសន្តតិកម្មនៃក្រមរដ្ឋប្បវេណី។

១៤- **សិទ្ធិប្រត្យក្ស** សំដៅទៅលើសិទ្ធិគ្រប់គ្រងលើវត្ថុដោយចំពោះ ដែលអាចអះអាងចំពោះបុគ្គលដទៃទៀតបាន។

១៥- **សេវារក្សាទុក** សំដៅដល់ការផ្ទេរទ្រព្យសម្បត្តិឬមូលនិធិដោយបុគ្គលណាមួយទៅឱ្យបរធនបាលដើម្បីរក្សាទុក ហើយប្រគល់ទៅឱ្យបុគ្គលផ្សេងទៀតឬប្រគល់ត្រឡប់ទៅឱ្យបុគ្គលនោះវិញ តាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងលិខិតបរធនបាលកិច្ច។

១៦- **អត្ថគាហកៈ** សំដៅដល់បុគ្គលដែលទទួលផលប្រយោជន៍ពីបរធនបាលកិច្ច។

១៧- **អ្នកផ្តល់វិភាគទានបរធនបាលកិច្ច** សំដៅដល់បុគ្គលដែលផ្តល់វិភាគទានទៅក្នុងបរធនបាលកិច្ច ឬបរធនបាលកិច្ចដែលមានស្រាប់ និងមានសិទ្ធិចូលរួមកំណត់លក្ខខណ្ឌនៃការបង់វិភាគទានដែលនឹងត្រូវគ្រប់គ្រង និងចាត់ចែងដោយបរធនបាល និងលក្ខខណ្ឌនៃការទទួលផលរបស់អត្ថគាហកៈ។

១៨- **អំណោយ** សំដៅដល់ការផ្ទេរទ្រព្យសម្បត្តិដោយស្ម័គ្រចិត្តពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតដោយគ្មានតម្លៃតបស្នងឬកាតព្វកិច្ចត្រឡប់។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL